# កូនសោទាំងឡាយនៃបព្វជិតភាពត្រូវបានស្តារឡើងវិញនៅក្នុងព្រះវិហារបរិសុទ្ធខឺតឡង់

**សកម្មភាពសិក្សាទី ក**
**គោលលទ្ធិ និងសេចក្តីសញ្ញា ១១០:១១**

ម៉ូសេបានស្តារឡើងវិញនូវកូនសោដើម្បី « ការប្រមូលសាសន៍អ៊ីស្រាអែល » ( គោលលទ្ធិ និងសេចក្តីសញ្ញា ១១០:១១ ) ។ កូនសោនៃការប្រមូលអនុញ្ញាតឲ្យពួកអ្នកបម្រើទាំងនោះកាន់សិទ្ធិអំណាចនេះដើម្បីផ្សព្វផ្សាយដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទដែលបានស្តារឡើងវិញដល់ប្រជាជាតិនៅលើផែនដីនេះ ។

ប្រធាន រ័សុល អិម ណិលសុន បានប្រកាស ៖



នៅពេលយើងនិយាយពីការប្រមូលផ្តុំអ៊ីស្រាអែលនៅទាំងសងខាងនៃវាំងនន ប្រាកដណាស់ យើងសំដៅលើកិច្ចការផ្សព្វផ្សាយសាសនា ព្រះវិហារបរិសុទ្ធ និងពង្សប្រវត្តិ ។ យើងក៏សំដៅលើការស្ថាបនាសេចក្តីជំនឿ និងទីបន្ទាល់នៅក្នុងដួងចិត្តនៃជនទាំងឡាយណាដែលយើងរស់នៅជាមួយ ធ្វើការជាមួយ និងបម្រើ ។ ( រ័សុល អិម ណិលសុន « Let God Prevail » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០២០ ទំព័រ ៩២ )

•តើអ្នកអាចជួយស្ថាបនាសេចក្តីជំនឿ និងទីបន្ទាល់នៅក្នុងដួងចិត្តអស់អ្នកដែលអ្នកទំនាក់ទំនងជាមួយជារៀងរាល់ថ្ងៃដោយរបៀបណា ?

- តើជីវិតរបស់អ្នក ឬជីវិតរបស់មនុស្សម្នាក់ដែលអ្នកស្គាល់បានទទួលឥទ្ធិពលដោយព្រះអម្ចាស់យោងមករកយើងតាមរយៈកិច្ចការផ្សព្វផ្សាយសាសនាដោយរបៀបណា ?

**សកម្មភាពសិក្សាទី ខ**
**គោលលទ្ធិ និងសេចក្តីសញ្ញា ១១០:១២**

អេលីយ៉ាសបានធ្វើការកាន់កាប់ត្រួតត្រានៃដំណឹងល្អរបស់អ័ប្រាហាំ ( សូមមើល គោលលទ្ធិ និងសេចក្តីសញ្ញា ១១០:១២ ) ។ ការណ៍នេះរួមទាំងការស្តារឡើងវិញនូវសេចក្តីសញ្ញាអ័ប្រាហាំផងដែរ ។

ប្រធាន រ័សុល អិម ណិលសុន បានពន្យល់ ៖



សេចក្តីសញ្ញាដែលព្រះបានធ្វើជាមួយអ័ប្រាហាំ. . .មាននូវការសន្យាជាច្រើន រួមទាំង. . .គ្រប់ជាតិសាសន៍ទាំងអស់នៃផែនដីនឹងទទួលបានពរដោយពូជអំបូររបស់លោក។ . . .

. . . យើងបានទទួលនូវបព្វជិតភាពដ៏បរិសុទ្ធ និងដំណឹងល្អដ៏អស់កល្បអស់កាលជានិច្ច ដូចពួកគេកាលពីជំនាន់បុរាណបានទទួលដែរ ។ យើងមានសិទ្ធិទទួលភាពពេញលេញនៃដំណឹងល្អ រីករាយនឹងពរជ័យនៃបព្វជិតភាព ហើយមានភាពស័ក្តិសមនឹងពរជ័យដ៏អស្ចារ្យបំផុតរបស់ព្រះ—ជាពរជ័យនៃជីវិតដ៏អស់កល្បជានិច្ច ។ ( រ័សុល អិម ណិលសុន « Covenants » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ៨៧–៨៨ )